# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីស្ថាននរកក្នុងព្រះពុទ្ធសាសនា

web site: hoksavann.org

ថ្ងៃទី១ ឧសភា ២០០៥

ស្ថាននរកនិងអ្នកដែលទៅកើតក្នុងស្ថាននរក ដែលមាននិយាយនៅក្នុងព្រះពុទ្ធសាសនា គឺកើតឡើងដោយអកុសលកម្ម ដែលមនុស្សសត្វបានកសាង ពុំមែនកើតពីព្រះជាម្ចាស់អង្គណាបង្កើតឡើងសំរាប់ដាក់ទណ្ឌកម្មដល់អ្នកដែលពុំជឿឡើយ ។ ពាក្យថានរកចេញពីសព្ទថា និរយៈ ដែលប្រែថាគ្មានសេចក្ដីចំរើន គ្មានសេចក្ដីសុខ គឺមិនមានសេចក្ដីចំរើនដោយលាភយសទ្រព្យសុខសរសើរឡើយ មានតែសេចក្ដីទុក្ខតែម្យ៉ាង ពុំមានសេចក្ដីសុខ សូម្បីតែ១នាទីក៏គ្មានដែរ ។ ក្នុងអបាយភូមិ៤គឺ នរក ប្រេត តិរច្ឆាន និងអសុរកាយ គឺសត្វដែលកើតក្នុងឋាននរក មានសេចក្ដីទុក្ខជាងសត្វ ដែលកើតក្នុងឋានទាំងបី ។ ស្ថាននរកដែលពុទ្ធសាសនានិយាយនេះ គឺព្រះពុទ្ធបានសំដែង ពុំមែនអដ្ឋកថាបានថែងឡើយ ។ ក្នុងគម្ពីរអភិធម្ម ដែលសំដែងឡើងដោយព្រះពុទ្ធ មាននិយាយពីភពបី គឺកាមភព រូបភព និងអរូបភព ដែលស្ថាននរកស្ថិតនៅក្នុងកាមភពផ្នែកអបាយភូមិបួន ៖ នៅក្នុងទេវទូតសូត្រ និងនេមិរាជជាតកនៃគម្ពីរសុត្តន្តបិដក ក៏មាននិយាយពីស្ថាននរក ។ មួយទៀត ក្នុងប្រសូត្រមាននិយាយថា ព្រះមោគ្គល្លានជាសាវកឆ្វេងរបស់ព្រះពុទ្ធជាម្ចាស់ បាននិមន្តទៅស្ថានសួគ៌ និងស្ថាននរកដោយឫទ្ធិរបស់លោក ព្រមទាំងបានទទួលពាក្យផ្ដាំផ្ញើពីសត្វនរក ដែលកំពុងរងទុក្ខវេទនាផង ។

នៅក្នុងអភិធម្មបិដកនិយាយថា អកុសលចិត្ត១២គឺ លោភមូល៨ ទោសមូល២ និងមោហមូល២ ដែលជាឫសគល់អកុសលដែលនាំឲ្យសត្វប្រព្រឹត្តធ្វើអំពើបាបកម្ម ដែលនាំឲ្យមានផលវិបាកកើតក្នុងអបាយភូមិមានកើតក្នុងនរកជាដើម ។ ការប្រព្រឹត្តធ្វើឲ្យប៉ះពាល់ដល់សេចក្ដីសុខអ្នកដទៃ ដូចជាបៀតបៀនធ្វើឲ្យគេមានទុក្ខតាមផ្លូវកាយនិងតាមផ្លូវចិត្ត រហូតដល់ថ្នាក់បំបាត់ជីវិតគេ ធ្វើឲ្យគេបាត់បង់ទ្រព្យសម្បត្តិ ព្រាត់ប្រាស់ប្រពន្ធកូនចៅគេជាដើម នេះជាអំពើធ្លាក់នរក ។ ពុទ្ធសាសនាមាននិយាយអំពីនរកជាច្រើនប្រភេទ មានទោសធ្ងន់ស្រាលទៅតាមអំពើដែលបានប្រព្រឹត្ត ដូចជានរកឈ្មោះ សញ្ជីវនរក ប្រែថានរកមានជីវិតរស់ឡើងដោយខ្លួនឯង ។ សត្វនរកនេះ ត្រូវនាយនិរយបាលចាក់កាប់ដោយដាវលំពែងដាច់សាច់ចេញឈាមស្លាប់ភ្លាម រួចរស់ឡើងវិញត្រូវនាយនិរយបាលធ្វើទារុណកម្មដូចមុនសោយទុក្ខវេទនាស្រែកទ្រហោយំរហូតផុតបាបកម្ម ។ ព្រះពុទ្ធសំដែងថា សត្វធ្លាក់នរកនេះ ដោយទោសសម្លាប់មនុស្ស លួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃ លួចប្រពន្ធកូនអ្នកដទៃ រំលោភឬគេងប្រវ័ញ្ចយកដីអ្នកដទៃ។ នរកនេះមានអាយុ៥០០ឆ្នាំទិព្វ ។ ចំនួន៩លានឆ្នាំមនុស្សបានតែ១យប់១ថ្ងៃរបស់នរកនេះ ។ នរកមួយទៀតឈ្មោះ លោហកុម្ភីនរក ប្រែថានរកផ្ទះទង់ដែង ។ សត្វនរកនេះត្រូវរងទុក្ខវេទនានៅក្នុងខ្ទះនៃទង់ដែងដ៏ក្ដៅ លិចចុះទៅដល់បាតខ្ទះ៣ម៉ឺនឆ្នាំ ផុសឡើង៣ម៉ឺនឆ្នាំ លិចចុះអណ្ដែតឡើងតែយ៉ាងនេះ សោយទុក្ខរហូតអស់បាបកម្ម ។ ទោសធ្លាក់នរកនេះ ដោយការធ្វើបាបអ្នកមានគុណ ប្រមាថអ្នកមានសីល រំលោភយកប្រពន្ធកូនអ្នកដទៃខាងផ្លូវកាមគុណ ដូចរឿងសេដ្ឋីបុត្ត៤នាក់ប្រព្រឹត្តធ្វើអំពើបែបនេះ បានធ្លាក់ទៅសោយទុក្ខក្នុងលោហកុម្ភិនរកនេះ ។ នរកមួយទៀតឈ្មោះ សិម្ពលីនរក ប្រែថានរកដើមរកា ។ ដើមរកានេះ មានបន្លាច្រូងច្រាងស្រួចមុតដូចកាំបិតកោរ ។ នាយនិរយបាលដេញទៅចាប់សត្វនរក ឲ្យឡើងដើមរកានេះ ត្រូវបន្លាមុតចេញឈាមហូរសស្រាក់ស្រែកទ្រហោយំ ថែមទាំងមានត្មាតដេញចឹកពីក្រោមថែមទៀត ។ រងទុក្ខវេទនាតែយ៉ាងនេះរាល់ថ្ងៃ រហូតអស់បាបកម្ម ។ ក្នុងអដ្ឋកថានិយាយថា នាយនិរយបាលដែលធ្វើទារុណកម្មដល់សត្វនរក កើតឡើងដោយអំពើបាបរបស់សត្វ ។ ទោសនៃការធ្លាក់នរកនេះ ដោយការប្រព្រឹត្តខុសកាមេសុមិច្ឆាចារៈ គឺការប្រព្រឹត្តកន្លងប្រពៃណីកូនប្រពន្ធប្ដីអ្នកដទៃ គឺលួចប្រពន្ធលួចប្ដីលួចកូនក្រមុំអ្នកដទៃ ។ ពាក្យខ្មែរក៏បានពោលថា កុំលួចប្រពន្ធកូនអ្នកដទៃ ប្រយ័ត្នឡើងដើមរកាដែក ។

តាមការអធិប្បាយមកនេះបញ្ជាក់ថា គម្ពីរព្រះពុទ្ធសាសនាបាននិយាយថាស្ថាននរកមានពិតមែន ហើយជាតួព្រះពុទ្ធដីកាបានសំដែងថែមទៀត តើស្ថាននរកនោះមានទីតាំងនៅកន្លែងណា ? ហេតុអ្វីបានជាក្រុមវិទ្យាសាស្ត្រស្រាវជ្រាវពុំឃើញ ? ខ្លះថានរកស្ថិតនៅក្នុងខ្លួនយើងនេះឯង គឺបើយើងកើតទុក្ខ ឈ្មោះថាយើងចុះនរកហើយ ។ ខ្លះថាអ្នកធ្លាក់នរកសំដៅយកអ្នកធ្វើអំពើអាក្រក់ធ្ងន់ៗ ឈ្មោះថាគេចុះនរកហើយ ។ ទាំងអស់នេះជាពាក្យដែលគេនិយាយអំពីនរកក្នុងជីវិតមនុស្សក្នុងស្ថានមនុស្ស ពុំបានចង្អុលបង្ហាញត្រង់ណាជាស្ថាននរកពិតប្រាកដទេ ។ សៀវភៅខ្លះសរសេរថា នរកស្ថិតនៅឆ្ងាយពីផែនដីរាប់ពាន់រាប់ម៉ឺនយោជន៍ ។ អ្នកខ្លះបើនិយាយពីស្ថាននរក គេចង្អុលចុះក្រោម គឺនរកនៅក្រោមដី ។

សេចក្ដីពិត នរកមានស្ថានមួយសំរាប់សត្វនរកពិតប្រាកដ ពុំមែនស្ថិតនៅក្រោមដី ឬនៅឆ្ងាយពីផែនដីឡើយ ដោយសំអាងលើរឿងរ៉ាវក្នុងសុត្តន្តបិដក ជាពិសេសរឿងនៅក្នុងគម្ពីរធម្មបទជាច្រើនកន្លែងដែលនិយាយថា ជាច្រើនដង ព្រះពុទ្ធបានធ្វើព្រះភ័ក្ត្រញញឹម សាវករបស់ព្រះអង្គបានទូលសួរអំពីការញញឹមនេះ, ព្រះអង្គបានសំដែងអំពីសត្វនរកឬប្រេតដែលព្រះអង្គបានទតឃើញ នៅលើផែនដីមានស្ថិតនៅលើភ្នំគិជ្ឈកូដជាដើម ។ ពេលខ្លះព្រះមោគ្គល្លាននិងសារីបុត្របានទតឃើញដោយមានសាក្សី ទើបព្រះអង្គជាម្ចាស់សំដែងអំពីបុព្វកម្មនៃសត្វប្រេតនិងសត្វនរកទាំងនោះ ។ ដូច្នេះបញ្ជាក់ថា សត្វនរកនិងសត្វប្រេតស្ថិតនៅលើផែនដីនេះឯង ប៉ុន្តែជាធាតុមួយផ្សេងពីធាតុរបស់មនុស្ស ដែលគេពុំអាចមើលឃើញឡើយ សូម្បីយកអតិសុខុមទស្សន៍របស់អ្នកវិទ្យាសាស្ត្រ ដែលអាចពង្រីកបានរាប់រយពាន់ដងក៏ដោយ ក៏ពុំអាចមើលសត្វនរកឬស្ថាននរកឃើញឡើយ ពីហួសវិស័យពីក្រុមវិទ្យាសាស្ត្រផ្នែកសម្ភារនិយម ដែលអាចមើលឃើញដោយមំសចក្ខុ គឺដោយភ្នែកធម្មតា ឬដោយប្រដាប់សំរាប់ឆ្លុះឡើយ ។ ពុទ្ធសាសនាបានពោលថា គេអាចមើលឃើញសត្វនរកនិងសត្វប្រេតបាន ដោយការអប់រំចិត្តរហូតកើតឈានចិត្តជាអប្បនាចិត្ត ហើយចំរើនឲ្យកើតអភិញ្ញាជាទិព្វចក្ខុ ទើបឃើញអបាយសត្វទាំងនោះ ។ មួយផ្នែកទៀត ក្នុងអភិធម្មផ្នែកកាមាចេរចិត្តខាងអកុសលនិយាយថា មនុស្សសត្វដែលសាងបាបកម្ម ពេលជិតដាច់ខ្យល់ស្លាប់មាននិមិត្តបីប្រភេទបានកើតឡើង និមិត្តបែបណាមួយឲ្យអ្នកជិតស្លាប់នោះឃើញ គឺកម្ម, កម្មនិមិត្តនិងគតិនិមិត្ត ។ ចំពោះគតិនិមិត្តផ្នែកអកុសល ឃើញនាយនិរយបាលមកចាប់ចងខ្លួន ហើយអូសទាញទៅ ជាសញ្ញាថា អ្នកនោះស្លាប់ទៅពិតជាទៅសោយទុក្ខក្នុងនរក ។ អាថ៌កំបាំងក្នុងលោកមានច្រើនណាស់ ដែលក្រុមវិទ្យាសាស្ត្រកំពុងរុករក ឬពុំអាចរកឃើញមានស្ថាននរកនេះជាដើម ។ ប៉ុន្តែក្រុមវិទ្យាសាស្ត្រទាំងនោះ នៅរក្សាគោលគំនិតមួយថា គេពុំបដិសេធនូវអ្វីមួយដែលគេពុំអាចរកឃើញនោះទេ គេទុកជាកម្មវត្ថុសំរាប់ស្រាវជ្រាវតទៅទៀត ។ អ្នកកសាងបាបក្នុងលោកនេះត្រូវទទួលទោសទណ្ឌកម្មក្នុងបច្ចុប្បន្នដោយច្បាប់រដ្ឋ ហើយស្លាប់ទៅនឹងធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិមាននរកជាដើម ។៚